00512925

D130/7/3/5


ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

អង្គបុរេជំនុំជម្រះ
Pre-Trial Chamber
Chambre Préliminaire


តាមនាមប្រជារាស្ត្រខ្មែរ និងតាមនាមអង្គការសហប្រជាជាតិ និងអនុលោមតាមច្បាប់ស្តីពី
ការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្ម
ដែលបានប្រព្រឹត្តឡើងក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 10 / 05 / 2010
ម៉ោង (Time/Heure): 11:00
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: Ratanak

សំណុំរឿងព្រហ្មទណ្ឌលេខ: ០០២/០៧-១២-២០០៧-អវតក/អបជ(៣១)

ចំពោះមុខ: ចៅក្រម ប្រាក់ គឹមសាន, ប្រធាន
ចៅក្រម Rowan DOWNING
ចៅក្រម នេយ ថុល
ចៅក្រម Katinka LAHUIS
ចៅក្រម ហួត វុទ្ធី

កាលបរិច្ឆេទ: ១០ ខែ ឧសភា ឆ្នាំ២០១០

---

**សាធារណៈ**

# សាលដីកាសម្រេចលើការទទួលយកបណ្តឹងឧទ្ធរណ៍របស់លោក អៀង សារី ប្រឆាំងនឹង ការបដិសេធតាមការសន្មតរបស់ ក.ស.ច.ស លើសំណើរបស់លោក អៀង សារី ទាក់ទងនឹង ការទទួលស្គាល់របស់ ក.ស.ច.ស នូវភស្តុតាង និងការសំអាងទៅលើភស្តុតាង ដែលទទួលបានតាមរយៈការធ្វើទារុណកម្ម

---

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 10 / 05 / 2010
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Ratanak

**សហព្រះរាជអាជ្ញា**
ជា លាង
Andrew CAYLEY
យ៉ែត ចរិយា
William SMITH
សេង ប៊ុនឃាង
Anees AHMED

**ជនត្រូវចោទ**
អៀង សារី

PRE-TRIAL CHAMBER * E.C.C.C. * C.E.T.C. * CHAMBRE PRÉLIMINAIRE

០០២/០៧-១២-២០០៧-អវតក/អបជ(៣១)

លេខ/No.D130/7/3/5

**មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី**

នី ចាន់ឌី

Mahdev MOHAN
NGUYEN Lyma

គីម ម៉េងឃី

ម៉ុច សុវណ្ណារី

Elizabeth-Joelle RABESANRATANA
Annie DELAHAIE
Philippe CANONNE
Martine JACQUIN
Fabienne TRUSSES-NAPROUS
Françoise GAUTRY
Issabelle DURAND
Christine MARTINEAU
Laure DESFORGES
Ferdinand DJAMMEN

ឡោ ជុនធី

ស៊ិន សុវ៉ន

សំ សុខគង់

ហុង គីមសួន

គង់ ពិសី

គង់ ហេង

Silke STUDZINSKY
Olivier BAHOUGNE
Marie GUIRAUD
Patrick BAUDOUIN

ជេត វណ្ណលី

ពេជ អង្គ

Julien RIVET
Pascal AUBOIN

**សហមេធាវីការពារក្ដី**

អាង ឧត្ដម

Michael G. KARNAVAS

០០២/០៧-១២-២០០៧-អវតក/អបជ(៣១)

លេខ/No.D130/7/3/5

**អង្គបុរេជំនុំជម្រះ**នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (**អ.វ.ត.ក**) បានទទួល "បណ្តឹងឧទ្ធរណ៍របស់ **អៀង សារី** ប្រឆាំងនឹងដីកាបដិសេធតាមការសន្មតរបស់ ក.ស.ច.ស លើសំណើសុំរបស់ អៀង សារី ទាក់ទងនឹងការទទួលស្គាល់របស់ ក.ស.ច.ស នូវភស្តុតាង និងការសំអាងទៅលើភស្តុតាងដែលទទួលបានតាមរយៈការធ្វើទារុណកម្ម" ដែលសហមេធាវីជនត្រូវចោទបានដាក់ជូននៅថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០០៨ (បណ្តឹងឧទ្ធរណ៍)[១]។

## I. ប្រវត្តិនីតិវិធី

១. នៅថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០០៨ សហមេធាវីជនត្រូវចោទបានដាក់សំណើមួយជូនសហចៅក្រមស៊ើបអង្កេត ទាក់ទងនឹងការទទួលស្គាល់របស់ ក.ស.ច.ស នូវភស្តុតាង និងការសំអាងទៅលើភស្តុតាងដែលទទួលបានតាមរយៈការធ្វើទារុណកម្ម (សំណើសុំទី១)[២]។

២. នៅថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០០៨ សហចៅក្រមស៊ើបអង្កេតបានជូនដំណឹងជាផ្លូវការដល់សហមេធាវីជនត្រូវចោទថា "ក្នុងប៉ុន្មានថ្ងៃខាងមុខនេះ" ខ្លួននឹងចេញដីកាសម្រេចដែល "នឹងឆ្លើយតបទៅនឹងបញ្ហាទាំងឡាយដែលសហមេធាវីបានលើកឡើង"(លិខិតរបស់សហចៅក្រមស៊ើបអង្កេត ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០០៨)[៣] ហើយនៅថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០០៨ សហចៅក្រមស៊ើបអង្កេត

---

[១] បណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាបដិសេធរបស់ ក.ស.ច.ស លើសំណើសុំរបស់ អៀង សារី ទាក់ទងនឹងការទទួលស្គាល់របស់ ក.ស.ច.ស នូវភស្តុតាង និងការសំអាងទៅលើភស្តុតាងដែលបានមកតាមរយៈការធ្វើទារុណកម្ម ចុះថ្ងៃ ទី១៩ ខែវិច្ឆិកា ឆ្នាំ២០០៨, ឯកសារ D130/7/3។

[២] សំណើសុំរបស់ អៀង សារី ទាក់ទងនឹងការទទួលស្គាល់របស់ ក.ស.ច.ស នូវភស្តុតាង និងការសំអាងទៅលើភស្តុតាងដែលបានមកតាមរយៈការធ្វើទារុណកម្ម ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០០៨, ឯកសារ D130/7។

[៣] "ចម្លើយតបទៅនិងលិខិតចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០០៨ ទាក់ទងនឹងការទទួលស្គាល់របស់ ក.ស.ច.ស នូវភស្តុតាង និងការសំអាងទៅលើភស្តុតាងដែលបានមកតាមរយៈការធ្វើទារុណកម្ម" ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០០៨, ឯកសារ D130/7/1។

បានចេញ "ដីកាសម្រេចលើការប្រើប្រាស់ភស្តុតាងដែលបានមក ឬដែលអាចបានមកដោយការធ្វើទារុណកម្ម" (ដីកាសម្រេច)[៤]។

៣. នៅថ្ងៃទី៧ ខែសីហា ឆ្នាំ២00៩ សហមេធាវីជនត្រូវចោទបានដាក់សំណើមួយទៀតជូនសហចៅក្រមស៊ើបអង្កេត ទាក់ទងនឹងការទទួលស្គាល់របស់ ក.ស.ច.ស នូវភស្តុតាង និងការសំអាងទៅលើភស្តុតាងដែលបានមកតាមរយៈការធ្វើទារុណកម្ម (សំណើសុំទី២)[៥]។

៤. សហមេធាវីជនត្រូវចោទបានដាក់បណ្តឹងឧទ្ធរណ៍នេះ នៅថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២00៩។

៥. សហព្រះរាជអាជ្ញាបានដាក់សារណាឆ្លើយតបចំពោះបណ្តឹងឧទ្ធរណ៍នេះ(ចម្លើយតបរបស់សហព្រះរាជអាជ្ញា)[៦] នៅថ្ងៃទី២ ខែធ្នូ ឆ្នាំ២00៩ ។

៦. នៅថ្ងៃទី៩ ខែធ្នូ ឆ្នាំ២00៩ អង្គបុរេជំនុំជម្រះបានណែនាំឱ្យសហមេធាវីជនត្រូវចោទ បញ្ជាក់ពីទស្សនៈរបស់ខ្លួនពាក់ព័ន្ធទៅនឹងបញ្ហានៃភាពអាចទទួលយកបាន ដែលសហព្រះរាជអាជ្ញាបានលើកឡើងក្នុងចម្លើយតបរបស់ខ្លួន (សេចក្តីបង្គាប់អង្គបុរេជំនុំជម្រះ)[៧]។

---

[៤] ដីកាសម្រេចលើការប្រើប្រាស់ភស្តុតាងដែលបានមក ឬដែលអាចបានមកដោយការធ្វើទារុណកម្ម ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២00៩ ឯកសារលេខ D130/8។

[៥] លិខិតសុំរបស់ អៀង សារី ទាក់ទងនឹងការទទួលស្គាល់របស់ ក.ស.ច.ស នូវភស្តុតាង និងការសំអាងទៅលើភស្តុតាងដែលបានមកតាមរយៈការធ្វើទារុណកម្ម ចុះថ្ងៃទី៧ ខែសីហា ឆ្នាំ២00៩ D130/7/2។

[៦] ចម្លើយតបរបស់សហព្រះរាជអាជ្ញា ទៅនឹងបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងការបដិសេធតាមការសន្មតរបស់សហចៅក្រមស៊ើបអង្កេតទៅលើសំណើរបស់ខ្លួន ទាក់ទងនឹងការទទួលស្គាល់របស់ ក.ស.ច.ស នូវភស្តុតាង និងការសំអាងទៅលើភស្តុតាងដែលបានមកតាមរយៈការធ្វើទារុណកម្ម ចុះថ្ងៃទី២ ខែធ្នូ ឆ្នាំ២00៩ D130/7/3/2។

[៧] សេចក្តីបង្គាប់ដល់សហមេធាវីការពារក្តីជនត្រូវចោទ អៀង សារី ឱ្យបញ្ចេញមតិយោបល់លើបញ្ហាស្តីពីភាពអាចទទួលយកបាន ដែលបានលើកឡើងដោយសហព្រះរាជអាជ្ញានៅក្នុងចម្លើយតបរបស់ខ្លួនទៅនឹងបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី៩ ខែធ្នូ ឆ្នាំ២00៩ D130/7/3/3។



E.C.C.C * C.E.T.C
PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE

៧. សហមេធាវីជនត្រូវចោទ បានដាក់ចម្លើយតបរបស់ខ្លួន (ចម្លើយតបរបស់សហមេធាវី)[៨] នៅថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ។

## II. សេចក្តីសន្និដ្ឋានរបស់ភាគី

៨. ក្នុងបណ្តឹងឧទ្ធរណ៍របស់ខ្លួន សហមេធាវីបានស្នើសុំឱ្យអង្គបុរេជំនុំជម្រះ ១) ប្រកាសទទួលយកបណ្តឹងឧទ្ធរណ៍នេះ ២) បើកសវនាការសាធារណៈ ៣) ច្រានចោលដីកាបដិសេធតាមការសន្មតរបស់សហចៅក្រមស៊ើបអង្កេតលើសំណើរបស់មេធាវីការពារក្តី និង៤) បង្គាប់ឱ្យសហចៅក្រមស៊ើបអង្កេតដាក់ព័ត៌មាន ដែលសហមេធាវីបានស្នើក្នុងសំណើសុំទី១ចូលក្នុងសំណុំរឿង និងដូចបានបញ្ជាក់ក្នុងកថាខណ្ឌទី២ នៃបណ្តឹងឧទ្ធរណ៍នេះ[៩]។

៩.សហមេធាវីជនត្រូវចោទបានអះអាងថា បណ្តឹងឧទ្ធរណ៍នេះអាចទទួលយកបាន តាមវិធាន ៥៥(១០) និងវិធាន ៧៤(៣)(ខ) នៃវិធានផ្ទៃក្នុង ថាជា "បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបដិសេធតាមការសន្មតលើសំណើសុំបើកកិច្ចស៊ើបសួរ"។ សហមេធាវីបានអះអាងថា "ការខកខានរបស់សហចៅក្រមក្នុងការសម្រេចលើសំណើសុំនោះ មិនផ្តល់លទ្ធភាពឱ្យជនត្រូវចោទទទួលបានផលប្រយោជន៍ដែលជនត្រូវចោទបានស្វែងរកឡើយ"[១០]។

---

[៨] ចម្លើយតបរបស់ អៀង សារី ទៅនឹងចម្លើយតបរបស់សហព្រះរាជអាជ្ញា ចំពោះបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងការបដិសេធតាមការសន្មតរបស់ កសចស នូវសំណើរបស់ អៀង សារី ទាក់ទងនឹងការទទួលស្គាល់ និងការសំអាងរបស់ ក.ស.ច.ស ទៅលើភស្តុតាងដែលបានមកតាមរយៈការធ្វើទារុណកម្ម ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ D130/7/3/4។

[៩] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ៥៨។

[១០] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ៤១-៤២។



PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C * C.E.T.C

១០. ក្នុងសារណាឆ្លើយតបរបស់ខ្លួន សហព្រះរាជអាជ្ញាបានស្នើសុំឱ្យអង្គបុរេជំនុំជម្រះច្រានចោលបណ្តឹងឧទ្ធរណ៍ ដោយសារបណ្តឹងនេះមិនអាចទទួលយកបាន[11] ហើយបានកត់សំគាល់ថា ១) ប្រសិនបើមេធាវីការពារព្យាយាមតវ៉ានឹងដីកាសម្រេចនោះ នោះបណ្តឹងឧទ្ធរណ៍របស់ខ្លួនយឺត ក្រោយពេលកំណត់[12] និង២) រីឯផ្នែកនៃសំណើដែលមិនបានឆ្លើយតបក្នុងដីកាសម្រេចនោះ គឺជនត្រូវចោទគ្រាន់តែបានស្វែងរក“ព័ត៌មាន” ពីសហចៅក្រមស៊ើបអង្កេត តែមិនមែនជាសំណើសុំបើកកិច្ចស៊ើបសួរឡើយ ដូច្នេះបណ្តឹងឧទ្ធរណ៍នេះមិនអាចទទួលយកបានឡើយ[13]។

១១. ក្នុងការឆ្លើយតបរបស់ខ្លួន សហមេធាវីជនត្រូវចោទបានអះអាងថា ដោយសារតែដីកាសម្រេចនោះមិនបានដោះស្រាយបញ្ហាដែលបានស្នើសុំ និងមិនបានយោងទៅរកសំណើសុំទី១[14]របស់ខ្លួន នាំឱ្យបណ្តឹងឧទ្ធរណ៍នេះអាចទទួលយកបាន។

១២. សហមេធាវីជនត្រូវចោទបានលើកឡើងថា ព័ត៌មានដែលខ្លួនស្វែងរកក្នុងសំណើ ពិតជាបង្កើតបានជាសំណើសុំបើកកិច្ចស៊ើបសួរដែលអាចប្តឹងឧទ្ធរណ៍បានតាមវិធាន៥៥(១០)និងវិធាន៧៣(៤)(ខ) នៃវិធានផ្ទៃក្នុង ហើយសហចៅក្រមត្រូវតែចាត់ទុកសំណើទាំងនេះជាសំណើសុំការស៊ើបអង្កេតដែលត្រូវបើកកិច្ចស៊ើបសួរ ដោយសារការគ្មានព័ត៌មានទាំងនេះមានផលប៉ះ ពាល់ផ្ទាល់ទៅលើវិធីវាយតម្លៃការសន្និដ្ឋានលើអង្គហេតុរបស់សហចៅក្រមស៊ើបអង្កេត[15]។

១៣. សហមេធាវីជនត្រូវចោទបានអះអាងថែមទៀតថា បណ្តឹងឧទ្ធរណ៍នេះអាចទទួលយកបាន ដោយសារដីកាបដិសេធតាមការសន្មតរបស់សហចៅក្រមស៊ើបអង្កេត បំពានសិទ្ធិជាមូលដ្ឋានរបស់ជនត្រូវចោទក្នុងការទទួលបានការជំនុំជម្រះដោយយុត្តិធម៌ រាប់បញ្ចូលទាំងសិទ្ធិក្នុងការរៀបចំការការពារ

---

[11] ចម្លើយតបសប់សហព្រះរាជអាជ្ញា កថាខណ្ឌ ១១។

[12] ចម្លើយតបសប់សហព្រះរាជអាជ្ញា កថាខណ្ឌ ៤-៦។

[13] ចម្លើយតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៧-១០។

[14] ចម្លើយតបរបស់សហមេធាវី កថាខណ្ឌ ១។

[15] ចម្លើយតបរបស់សហមេធាវី កថាខណ្ឌ ២-៤។

រឿងក្តីរបស់ខ្លួនផងដែរ។ សហមេធាវីបានបញ្ជាក់ពីលទ្ធភាពថាបណ្តឹងឧទ្ធរណ៍នេះ អាចទទួលយកបាន តាមវិធាន២១[១៦] នៃវិធានផ្ទៃក្នុង។

## III. ច្បាប់ជាធរមាន

១៤. បណ្តឹងឧទ្ធរណ៍នេះយោងតាមវិធាន ២១, ៥៥(១០), ៧៣, ៧៤(៣) និងវិធាន ៧៥ នៃវិធានផ្ទៃក្នុង និងមាត្រា ១៤(៣)(ខ) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ។

## IV. ការពិចារណារបស់អង្គបុរេជំនុំជម្រះ

១៥. អង្គបុរេជំនុំជម្រះសង្កេតឃើញថា ក្នុងបណ្តឹងឧទ្ធរណ៍របស់ខ្លួន សហមេធាវីបានតវ៉ាពីការបដិសេធតាមការសន្មតលើសំណើរបស់ខ្លួន ហើយសុំឲ្យអង្គបុរេជំនុំជម្រះ "បង្គាប់ឲ្យសហចៅក្រមស៊ើបអង្កេតបន្ថែមព័ត៌មានដែលមេធាវីការពារក្តីបានស្នើសុំក្នុងសំណើទី១ ទៅក្នុងសំណុំរឿង"[១៧]។

១៦. អង្គបុរេជំនុំជម្រះកត់សំគាល់ឃើញថា សំណើសុំទី១ ត្រូវបានដាក់ជូននៅថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០០៨។ នៅថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០០៨ សហចៅក្រមស៊ើបអង្កេតបានជូនដំណឹងជាផ្លូវការដល់សហមេធាវីជនត្រូវចោទថា "ក្នុងប៉ុន្មានថ្ងៃខាងមុខនេះ" ខ្លួននឹងចេញដីកាសម្រេចដែល "នឹងឆ្លើយតបទៅនិងបញ្ហាទាំងឡាយដែលសហមេធាវីបានលើកឡើង" ហើយសហចៅក្រមស៊ើបអង្កេតបានចេញដីកាសម្រេចនោះ នៅថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០០៨។

១៧. អង្គបុរេជំនុំជម្រះពិនិត្យឃើញថា ទោះបីជាមានអង្គហេតុថាដីកាសម្រេចនោះមិនបានយោងជាផ្លូវការទៅរកសំណើសុំទី១ក៏ដោយ ក៏លិខិតផ្លូវការមួយចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០០៨ របស់សហចៅក្រមស៊ើបអង្កេត បញ្ជាក់ច្បាស់ថា សហចៅក្រមស៊ើបអង្កេតមានចេតនាឆ្លើយតបនឹងសំណើទី១ របស់សហមេធាវី ក្នុងដីកាសម្រេចរបស់ខ្លួននោះដែរ។ លើសពីនេះទៅទៀត ដោយមិនចាំបាច់និយាយ

---

[១៦] ចម្លើយតបរបស់សហមេធាវី កថាខណ្ឌ ៥-៧។

[១៧] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ៥៨(ឃ)។



E.C.C.C * C.E.T.C. PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE

ដល់ខ្លឹមសារនៃដីកាសម្រេច អង្គបុរេជំនុំជម្រះសង្កេតឃើញដូច ការកត់សំគាល់របស់សហមេធាវីដែរ[១៨]ថា សហចៅក្រមស៊ើបអង្កេតពិតជាបានដោះស្រាយសំណើទី១ក្នុងដីកាសម្រេចរួចហើយ[១៩]។ ដូច្នេះ អង្គបុរេជំនុំជម្រះយល់ឃើញថា សហចៅក្រមស៊ើបអង្កេតមិនបានបដិសេធចោលបញ្ហាទាំងឡាយក្នុងសំណើទី១ តាមការសន្មតទេ។

១៨. អង្គបុរេជំនុំជម្រះបានសង្កេតឃើញថែមទៀតថា ដោយសារដីកាសម្រេចមានខ្លឹមសារអនុវត្តទូទៅ ដូច្នេះដីកាសម្រេចនេះមានអនុភាពលើជនត្រូវចោទទាំងអស់ក្នុងសំណុំរឿង ០០២ ដោយមិនគិតថាតើសហមេធាវីជនត្រូវចោទបានដាក់ ឬមិនដាក់សំណើទេ ឬថា តើសំណើនោះត្រូវបានចែង ឬមិនបានចែងក្នុងដីកាសម្រេចក៏ដោយ ក៏ជនត្រូវចោទមានសិទ្ធិប្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចនេះដែរ[២០]។ ភាគីមិនបានដាក់បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចនេះ ក្នុងរយៈពេលដូចបានកំណត់ក្នុងវិធាន ៧៥ នៃវិធានផ្ទៃក្នុងទេ ហើយភាគីក៏មិនបានស្នើសុំ ពន្យារពេលវេលានេះដែរ។

១៩. ចំពោះករណីសំណើទី២ អង្គបុរេជំនុំជម្រះបានសង្កេតឃើញថា ក្រោយពីបានដឹងថាដីកានោះសម្រេចពីសំណើទី២ លើ“បញ្ហាទូទៅដែលពាក់ព័ន្ធនឹងនីត្យានុកូលភាព និងការប្រើភស្តុតាងដែលបានមកពីអំពើទារុណកម្មក្នុងអំឡុងពេលកិច្ចស៊ើបសួរ” សហមេធាវីបានបញ្ជាក់ថា “ខ្លួនលើកយកបញ្ហាទាំងឡាយដែលស្នើក្នុងសំណើទី១ របស់ខ្លួនមកស្នើឡើងវិញ”។ ខ្លឹមសារសំណើទី២ បង្ហាញថា សហមេធាវីមិនពេញចិត្តនឹង“ចម្លើយទូទៅ” ដែលសហចៅក្រមស៊ើបអង្កេតបញ្ជាក់ក្នុងដីកាសម្រេចនោះទេ ហើយពួកគេបានទទូចចង់បានចម្លើយពិស្តារជាងនេះ ទៅនឹង “សំណួរជាក់លាក់” របស់គេនៅក្នុងសំណើទី១។

---

[១៨] សំណើទី២ កថាខណ្ឌទី២។

[១៩] សូមអានដីកាសម្រេច ជាពិសេស កថាខណ្ឌទី១៩, ២៦, ២៧ និង ២៩។

[២០] សេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះលើការទទួលយកបណ្តឹងឧទ្ធរណ៍ដែលដាក់ដោយ ខៀវ សំផន និងសេចក្តីបង្គាប់ដល់សហព្រះរាជអាជ្ញា ចុះថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០០៩ ឯកសារ D164/4/7 កថាខណ្ឌ ១២ (អបជ២៤)។ *សាលដីកាសម្រេចលើការទទួលយកបណ្តឹងឧទ្ធរណ៍របស់លោក អៀង សារី ប្រឆាំងនឹងការបដិសេធតាមការសន្មតរបស់ ក.ស.ច.ស លើសំណើរបស់លោក អៀង សារី ទាក់ទងនឹងការទទួលស្គាល់របស់ ក.ស.ច.ស នូវភស្តុតាង និងការសំអាង ទៅលើភស្តុតាងដែលទទួលបានតាមរយៈការធ្វើទារុណកម្ម*

២០. អង្គបុរេជំនុំជម្រះកត់សំគាល់ឃើញថា នីតិវិធីត្រឹមត្រូវសំរាប់ភាគីតវ៉ាពីស្ថានភាពចម្លើយក្នុងដីកាសម្រេចនេះ គឺបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកានេះ ហើយការដាក់សំណើថ្មីបន្ថែមលើសំណើមុនដែលត្រូវបានដោះស្រាយក្នុងដីកាសម្រេច មិនមែនជានីតិវិធីត្រឹមត្រូវទេ។ ដោយមិនគិតពីអង្គហេតុដូចលើកឡើងនេះ ឧបមាថាសហមេធាវីបានភ័ន្តច្រឡំដោយសារដីកាសម្រេចមិនបានយោងច្បាស់ទៅរកសំណើទី១ អង្គបុរេជំនុំជម្រះត្រូវពិនិត្យថាតើការគ្មានខ្លឹមសារយោងច្បាស់នេះ នឹងនាំឱ្យពួកគេមានសិទ្ធិប្តឹងឧទ្ធរណ៍ប្រឆាំងនឹងការបដិសេធតាមការសន្មតចំពោះ សំណើទី២ដែរឬទេ។ ដើម្បីកំណត់ពីយុត្តាធិការរបស់ខ្លួនលើបណ្តឹងឧទ្ធរណ៍នេះ អង្គបុរេជំនុំជម្រះត្រូវចាប់ផ្តើមធ្វើការពិនិត្យមើលស្ថានភាពសំណើដែលពាក់ព័ន្ធ។

២១. សំណើទី២ មិនបានបញ្ជាក់ពីមូលដ្ឋានច្បាប់ដែលគាំទ្រការដាក់សំណើជូនសហចៅក្រមស៊ើបអង្កេតទេ ហើយសំណើនោះមានគោលបំណង "ស្នើសុំព័ត៌មាន" និង"ស្នើដាក់បញ្ហាទាំងឡាយក្នុងសំណើទី១ឡើងវិញ"។ សំណើទី១ ក៏មិនបានបញ្ជាក់ពីមូលដ្ឋានច្បាប់ដែលគាំទ្រការដាក់សំណើជូនសហចៅក្រមស៊ើបអង្កេតផងដែរ ប៉ុន្តែសំណើនោះមានគោលបំណង ដូចបញ្ជាក់ក្នុងកថាខណ្ឌទី១ គឺ"ស្នើសុំព័ត៌មានជាផ្លូវការ"។ ក្រៅពីនេះ ដូចបានបញ្ជាក់ក្នុងកថាខណ្ឌទី១២ខាងលើ ក្នុងបណ្តឹងឧទ្ធរណ៍នោះ សហមេធាវីបានបញ្ជាក់ថាត្រូវតែចាត់ទុកសំណើរបស់ខ្លួនជាសំណើសុំការស៊ើបអង្កេតដែលត្រូវតែបើកកិច្ចស៊ើបសួរ ដូចបានកំណត់ក្នុងវិធាន ៥៥(១)។

២២. អង្គបុរេជំនុំជម្រះសង្កេតឃើញថា នៅក្នុងសំណើទី១ សហមេធាវីបានស្នើសុំឱ្យសហចៅក្រមស៊ើបអង្កេត "ផ្តល់សេចក្តីបញ្ជាក់ពីព័ត៌មានដូចខាងក្រោមនេះ៖

១. ថាតើដល់កំរិតណាហើយដែល ក.ស.ច.ស បានទទួលស្គាល់យ៉ាងច្បាស់លាស់នូវភស្តុតាងដែលមាននៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ដែលរួមបញ្ចូលនូវភស្តុតាង ដែលទទួលបានមកពីការធ្វើទារុណកម្ម។ ក្នុងចំណោមអ្វីផ្សេងទៀត ដីកានេះមានរួមបញ្ចូលនូវរបាយការណ៍នានា ឬការវិភាគទាំងឡាយដែលយកជាសំអាង ឬបង្កើតឡើងដោយ ក.ស.ព ដែលមានផ្ទុកនូវព័ត៌មានដែលទទួលបានដោយការធ្វើទារុណកម្ម។



PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C * C.E.T.C

២. ថាតើដល់កំរិតណាហើយដែល ក.ស.ច.ស បានទទួលស្គាល់យ៉ាងច្បាស់លាស់ នូវភស្តុតាងដែលកើតចេញពីព័ត៌មានដែលទទួលបានពីការធ្វើទារុណកម្ម។

៣. ថាតើដល់កំរិតណាហើយដែល ក.ស.ច.ស បានកំណត់នូវបទដ្ឋានស្តីពីអ្វីដែលបង្កើតបានជាព័ត៌មានដែលទទួលបានដោយការធ្វើទារុណកម្ម។

៤. ថាតើដល់កំរិតណាហើយដែល ក.ស.ច.ស បានបង្កើតសេចក្តីណែនាំស្តីពីការប្រើប្រាស់នូវព័ត៌មានដែលទទួលបានពីការធ្វើទារុណកម្ម។

៥. ថាតើដល់កំរិតណាហើយដែល ក.ស.ច.ស បានប្រើប្រាស់ព័ត៌មានដែលទទួលបានតាមរយៈរធ្វើទារុណកម្ម ដើម្បីធ្វើជាមធ្យោបាយដើម្បីប្រមូលព័ត៌មានបន្ថែមទៀត។

៦. ថាតើដល់កំរិតណាហើយដែល ក.ស.ច.ស មានចេតនាដើម្បីលាតត្រដាងដល់ជនត្រូវចោទនូវព័ត៌មានដែលខ្លួនមាន ដែល ក.ស.ច.ស ជឿជាក់ថាព័ត៌មាននោះគឺជាលទ្ធផលនៃការធ្វើទារុណកម្ម ឬដែលកើតចេញពីការធ្វើទារុណកម្ម"។

២៣. តាមការពិចារណាលើគោលបំណងក្នុងសំណើ អង្គបុរេជំនុំជម្រះសង្កេតឃើញថា សំណើទាំងនោះមិនមែនជា "សំណើសុំបើកកិច្ចស៊ើបសួរ" ដែលស្ថិតក្នុងវិសាលភាពវិធាន ៧៤(៣)(ខ) នៃវិធានផ្ទៃក្នុង និងតាមខ្លឹមសារដែលអង្គបុរេជំនុំជម្រះកំណត់ក្នុងសាលដីការបស់ខ្លួនលើបណ្តឹងឧទ្ធរណ៍របស់លោក ខៀវ សំផន[២១] ស្តីពីសិទ្ធិបកប្រែទេ។ សំណើទាំងនោះ មិនមែនជាសំណើសុំឲ្យសហចៅក្រមស៊ើបអង្កេតបើកកិច្ចស៊ើបសួរ ឬឲ្យអ្នកស៊ើបអង្កេតរបស់ អ.វ.ត.ក ឬនគរបាលយុត្តិធម៌បំពេញកិច្ចស៊ើបសួរតាមការផ្ទេរសិទ្ធិ ក្នុងគោលបំណងប្រមូលព័ត៌មាន ដែលមានប្រយោជន៍បញ្ជាក់ការពិតឡើយ។

---

[២១] សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់លោក ខៀវ សំផន ប្រឆាំងនឹងដីកាសម្រេចលើសិទ្ធិ និងកាតព្វកិច្ចរបស់ភាគីទាក់ទងនឹងការបកប្រែ ចុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០០៨ កថាខណ្ឌ ២៨ ឯកសារ A190/I/20។

*សាលដីកាសម្រេចលើការទទួលយកបណ្តឹងឧទ្ធរណ៍របស់លោក អៀង សារី ប្រឆាំងនឹងការបដិសេធតាមការសន្មតរបស់ ក.ស.ច.ស លើសំណើរបស់លោក អៀង សារី ទាក់ទងនឹងការទទួលស្គាល់របស់ ក.ស.ច.ស នូវភស្តុតាង និងការសំអាង ទៅលើភស្តុតាងដែលទទួលបានតាមរយៈការធ្វើទារុណកម្ម*

២៤. អង្គបុរេជំនុំជម្រះកត់សំគាល់ឃើញបន្ថែមទៀតថា ជាទូទៅខ្លួនគ្មានយុត្តាធិការពិនិត្យបញ្ហាដែលពាក់ព័ន្ធនឹងវិធីសាស្ត្រដែលសហចៅក្រមប្រើសំរាប់វាយតម្លៃ ឬទទួលយកភស្តុតាង ក្នុងខណៈដែលពួកគេអនុវត្តភារកិច្ចស្វែងរកការពិតឡើយ។ អនុលោមតាមវិធាន ៨៧ នៃ វិធានផ្ទៃក្នុង បញ្ហានៃការទទួលយកភស្តុតាង ត្រូវលើកឡើងនៅដំណាក់កាលជំនុំជម្រះនៃ ដំណើការនីតិវិធីព្រហ្មទណ្ឌ ក្នុងករណីដែលមានដីកាដំណោះស្រាយដែលបញ្ជូនជនត្រូវចោទ ទៅជំនុំជម្រះ។ មាត្រា ៣២១ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ក៏បានចែងអំពីការទទួលយក ភស្តុតាងក្នុងដំណាក់កាលជំនុំជម្រះដូចគ្នានេះដែរ។ វិធានទាំងនេះផ្តល់ឆន្ទានុសិទ្ធិទូលាយដល់ ចៅក្រមជំនុំជម្រះក្នុងការសម្រេចថា តើត្រូវទទួលយក ឬមិនទទួលយកភស្តុតាង។

២៥. ផ្អែកលើមូលហេតុទាំងនេះ អង្គបុរេជំនុំជម្រះយល់ឃើញថា ខ្លួនមិនអាចប្រកាសទទួលយកបណ្តឹងឧទ្ធរណ៍នេះ ដោយអនុវត្តតាមវិធាន ៥៥ និងវិធាន ៧៤ នៃវិធានផ្ទៃក្នុងបានទេ។

២៦. អង្គបុរេជំនុំជម្រះសង្កេតឃើញបន្ថែមទៀតថា សហមេធាវីក៏បានលើកឡើងផងដែរថា បណ្តឹងឧទ្ធរណ៍នេះអាចទទួលយកបាន ដោយសារការបដិសេធតាមការសន្មតលើសំណើរបស់សហចៅក្រមស៊ើបអង្កេត បង្កើតបានជាការបំពានយ៉ាងធ្ងន់ធ្ងរដែលគ្មានអ្វីអាចសងវិញបានឡើយ ទៅលើសិទ្ធិជាមូលដ្ឋានរបស់ជនត្រូវចោទក្នុងការទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ដែល រួមបញ្ចូលទាំង "សិទ្ធិទទួលបានថេរវេលា និងលក្ខណៈគ្រប់គ្រាន់សំរាប់រៀបចំការការពារក្តីរបស់ខ្លួន"[២២]។ សហមេធាវីបានលើកពីលទ្ធភាពនៃការទទួលយកបណ្តឹងឧទ្ធរណ៍នេះតាមវិធាន ២១ នៃវិធានផ្ទៃក្នុង។

២៧. វិធាន ២១ នៃវិធានផ្ទៃក្នុងចែងថា៖

**"វិធាន ២១: គោលការណ៍ជាសារវ័ន្ត**

១.ច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា វិធានផ្ទៃក្នុង សេចក្តីណែនាំអនុវត្ត និងបទបញ្ជារដ្ឋបាលទាំងអស់ជាធរមាន ត្រូវតែបកស្រាយក្នុងន័យការពារជានិច្ចដល់ប្រយោជន៍របស់ជនសង្ស័យ ជនត្រូវចោទជនជាប់ចោទ និង ជនរងគ្រោះ ដើម្បីធានាអំពីសច្ចភាពផ្លូវច្បាប់ និង កិច្ច

---

[២២] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ៤៩-៥៥។



E.C.C.C * C.E.T.C. PRE-TRIAL CHAMBER CHAMBRE PRELIMINAIRE

00512936



ដំណើរការនីតិវិធីប្រកបដោយតម្លាភាព ដោយគិតដល់លក្ខណៈពិសេសរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដូចមានចែងក្នុងច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និងកិច្ចព្រមព្រៀង។ ក្នុងបរិបទនេះ៖

ក-ដំណើរការនីតិវិធីនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញ ត្រូវតែមានយុត្តិធម៌ និង ត្រូវគោរពគោលការណ៍ចំពោះមុខ ហើយត្រូវរក្សាបាននូវតុល្យភាពរវាងសិទ្ធិរបស់ភាគីទាំងឡាយ។ នីតិវិធីត្រូវធានាឱ្យបាននូវភាពដាច់ដោយឡែកពីគ្នារវាងអាជ្ញាធរដែលទទួលបន្ទុកការចោទប្រកាន់ និង អាជ្ញាធរដែលទទួលបន្ទុកការវិនិច្ឆ័យទោស។

ខ-បុគ្គលទាំងឡាយដែលរកឃើញថា ស្ថិតនៅក្នុងស្ថានភាពស្រដៀងគ្នា និងត្រូវបានចោទប្រកាន់ចំពោះបទល្មើសដូចគ្នា ត្រូវយកវិធានដូចគ្នាមកអនុវត្ត។

គ-អង្គជំនុំជម្រះវិសាមញ្ញ ត្រូវធានាថា ជនរងគ្រោះត្រូវទទួលបានការជូនព័ត៌មាន ហើយសិទ្ធិរបស់ជនរងគ្រោះ ត្រូវបានការពារក្នុងអំឡុងពេលនៃដំណើរការនីតិវិធីរឿងក្តី។

ឃ-ជនណាដែលត្រូវបានសង្ស័យ ឬ ត្រូវបានចោទប្រកាន់ ត្រូវចាត់ទុកថាគ្មានទោស ដរាបណាពិរុទ្ធភាពរបស់គេមិនទាន់ត្រូវបានរកឃើញ។ ជនទាំងនេះមានសិទ្ធិទទួលដំណឹងអំពីបទល្មើស ដែលចោទប្រកាន់ចំពោះខ្លួន និងមានមេធាវីការពារតាមការជ្រើសរើសរបស់ខ្លួន ហើយនិងនៅក្នុងគ្រប់ដំណាក់កាលទាំងអស់នៃកិច្ចដំណើរការនីតិវិធីត្រូវផ្តល់ព័ត៌មានដល់គេ អំពីសិទ្ធិនៅស្ងៀមមិនឆ្លើយតប"។

២៨. អង្គបុរេជំនុំជម្រះត្រូវពិនិត្យថាតើវិធាន ២១ នៃវិធានផ្ទៃក្នុង តម្រូវ ឬមិនតម្រូវឱ្យបកស្រាយទូលាយអំពីសិទ្ធិប្តឹងឧទ្ធរណ៍របស់ជនត្រូវចោទ ដើម្បីធានាឱ្យដំណើរការនីតិវិធីមានយុត្តិធម៌ និងបានការពារដល់សិទ្ធិរបស់ជនត្រូវចោទផងដែរ។

២៩. អង្គបុរេជំនុំជម្រះសង្កេតឃើញថា សហមេធាវីបានសង្ខេបព័ត៌មានដែលខ្លួនស្នើសុំដូចខាងក្រោមនេះ៖



E.C.C.C * C.E.T.C * PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE

00512937



"[ព័ត៌មានស្តីពី] នីតិវិធី ឬពិធីការ ដែល[សហចៅក្រមស៊ើបអង្កេត] ប្រើជាបង្អែកក្នុងការសម្រេចពីភាពអាចជឿជាក់បាននៃចម្លើយសារភាពមួយចំនួន"[23]។

៣០. អង្គបុរេជំនុំជម្រះយល់ឃើញថា ក្នុងច្បាប់ទាំងឡាយដែលអនុវត្តចំពោះ អ.វ.ត.ក ឬ ក្នុងយុត្តិសាស្ត្ររបស់តុលាការអន្តរជាតិ ដែលពាក់ព័ន្ធនឹងមាត្រា ១៤(៣)(ខ) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ គ្មានបទប្បញ្ញត្តិណាមួយដែលចែងថា "អាជ្ញាធរស៊ើបអង្កេតត្រូវតែផ្តល់ព័ត៌មានស្តីពីនីតិវិធី និងពិធីសារ ដែលខ្លួនប្រើក្នុងអំឡុងពេលស៊ើបអង្កេត" តាមការស្នើសុំរបស់មេធាវីការពារក្តី ដើម្បីជួយសម្រួលដល់ការរៀបចំការការពារក្តីឡើយ។

៣១. ដូចដែលសហមេធាវីបានលើកឡើង[២៤] អង្គបុរេជំនុំជម្រះយល់ឃើញថា សិទ្ធិរបស់បុគ្គលក្នុងការមានលក្ខណៈគ្រប់គ្រាន់សំរាប់ការរៀបចំការការពារ រួមមានសិទ្ធិប្រាស្រ័យទាក់ទងជាមួយមេធាវី និងឱកាសរបស់ជនជាប់ចោទក្នុងការយល់ដឹងពីលទ្ធផលនៃកិច្ចស៊ើបសួរ និង មានពេលវេលាសមស្របសំរាប់រៀបចំការការពារក្តី[២៥]។ អង្គបុរេជំនុំជម្រះយល់ឃើញថា ពាក្យថា"លទ្ធផលនៃកិច្ចស៊ើបសួរ" មានន័យថា លទ្ធផលនៃការស៊ើបអង្កេត ដែលរួមមានឯកសារ និងកំណត់ត្រាទាំងឡាយក្នុងសំណុំរឿង ប៉ុន្តែមិនមែនព័ត៌មានស្តីពីនីតិវិធីដែលអាជ្ញាធរស៊ើបអង្កេតអនុវត្តតាមក្នុងការវាយតម្លៃភស្តុតាង ដែលពួកគេប្រមូលបានឡើយ។

---

[២៣] សំណើទី២ ប្រយោគចុងក្រោយ។

[២៤] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ៥០។

[២៥] ដើម្បីយល់អំពីអត្ថន័យឃ្លា "សម្ភារៈគ្រប់គ្រាន់សំរាប់ការរៀបចំការការពារ" សូមអានមាត្រា ១៤(៣)(ខ) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ និងយុត្តិសាស្ត្រគណៈកម្មាធិការសិទ្ធិមនុស្ស ៖ *រឿងក្តី Aston Little ទល់នឹង Jamaica* លេខ ២៨៣/១៩៨៨, *O.F. ទល់នឹង Norway* លេខ ១៥៨/១៩៨៣, *Wight ទល់នឹង Madagasca* លេខ ១១៥/១៩៨២, *Pietraroia ទល់នឹង Uraguay* លេខ ៤៤/១៩៧៩, *Drescher Caldas ទល់នឹង Uraguay* លេខ ៤៣/១៩៧៩, Lafuente Penarrieta ទល់នឹង Bolivia លេខ ១៧៦/១៩៨៤, ចូរអានមាត្រា ៦(៣)(ខ) នៃអនុសញ្ញាសិទ្ធិមនុស្សអឺរ៉ុប, *សាលដីការឿងក្តី Campbell and Fell ទល់នឹង UK* លេខ A ៨0 (១៩៨4), *រឿងក្តី Jespers ទល់នឹង Belgium* លេខ ៨៤០៣.៧៨។



PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C. C.E.T.C.

00512938



៣២. ភាគីនឹងបានឃើញភាពសមតាមវិចារណញ្ញាណនៃការវិភាគភស្តុតាង នៅពេលមានដីកាដំណោះស្រាយ ដែលត្រូវបានចេញនៅពេលបញ្ចប់កិច្ចស៊ើបសួរ ទោះបីដីកានោះជាដីកាបញ្ជូនរឿងទៅជំនុំជម្រះ ឬជាដីកាលើកលែងការចោទប្រកាន់ក្តី។ វិធាន ៦៧(៤) នៃវិធានផ្ទៃក្នុងចែងថា ដីកាដំណោះស្រាយត្រូវតែមានសំអាងហេតុគាំទ្រសេចក្តីសម្រេចបញ្ជូនជនត្រូវចោទទៅជំនុំជម្រះ ឬលើកលែងការចោទប្រកាន់ចំពោះករណីណាមួយ។

៣៣. អង្គបុរេជំនុំជម្រះកត់សំគាល់ឃើញថា រហូតមកដល់ពេលនេះ តុលាការបានចំណាយពេលពីរឆ្នាំកន្លះសំរាប់ដំណើរការនីតិវិធីមុនអង្គសេចក្តី ហើយរំពឹងថានឹងចេញដីកាដំណោះស្រាយ ឲ្យបានមុនផុតរយៈពេលបីឆ្នាំ។ បន្ទាប់ពីចេញដីកាដំណោះស្រាយ ប្រសិនបើមានដីកាបញ្ជូនក្តីរបស់ខ្លួនទៅជំនុំជម្រះ សហមេធាវីជនត្រូវចោទមានពេលរៀបចំការការពាររបស់ខ្លួន សំរាប់ដំណាក់កាលជំនុំជម្រះតាមរយៈការពិនិត្យភស្តុតាងដែលខ្លួនអាចពិនិត្យមើលបាន[២៦]។ ដូច្នេះ អង្គបុរេជំនុំជម្រះនឹងមិនពិភាក្សាពិស្តារពីការលើកឡើងថា មេធាវីការពារក្តីមិនមានពេលសមស្រប សំរាប់រៀបចំការការពារក្តីនោះឡើយ។

៣៤. អង្គបុរេជំនុំជម្រះសង្កេតផងដែរថា វិធាន ៨៧ នៃវិធានផ្ទៃក្នុង ក៏បានផ្តល់លទ្ធភាពឲ្យជនត្រូវចោទជំទាស់នឹងការទទួលយកភស្តុតាងក្នុងដំណាក់កាលជំនុំជម្រះផងដែរ[២៧]។

៣៥. អង្គបុរេជំនុំជម្រះក៏កត់សំគាល់ផងដែរថា នីតិវិធីដែលអង្គជំនុំជម្រះសាលាដំបូងបានអនុវត្តក្នុងការវាយតម្លៃភស្តុតាងសំរាប់ការជំនុំជម្រះ គឺអនុលោមតាមបទដ្ឋានច្បាប់អន្តរជាតិ និងការពារសិទ្ធិជនត្រូវចោទក្នុងការទទួលបានការជំនុំជម្រះដោយយុត្តិធម៌ផងដែរ។ អង្គជំនុំជម្រះសាលាដំបូងនៃ អ.វ.ត.ក ក៏ទទួលបានឆន្ទានុសិទ្ធិក្នុងការច្រានចោលសំណើសុំដាក់ភស្តុតាង ដូចគ្នានឹងឆន្ទានុសិទ្ធិដែល

---

[២៦] វិធាន ៥៥(៦) នៃវិធានផ្ទៃក្នុង។

[២៧] ដើម្បីយល់ច្បាស់ពីបទប្បញ្ញត្តិវិធាន ៨៧ នៃវិធានផ្ទៃក្នុង ចូរអានសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី ២៦ ខែឧសភា ឆ្នាំ២00៩ ស្តីពីការទទួលយកសម្ភារៈ/ឯកសារ ក្នុងសំណុំរឿងជាភស្តុតាង E43/4 កថាខណ្ឌ ៥-៧។ *សាលដីកាសម្រេចលើការទទួលយកបណ្តឹងឧទ្ធរណ៍របស់លោក អៀង សារី ប្រឆាំងនឹងការបដិសេធតាមការស្នើរបស់ ក.ស.ច.ស លើសំណើរបស់លោក អៀង សារី ទាក់ទងនឹងការទទួលស្គាល់របស់ ក.ស.ច.ស នូវភស្តុតាង និងការសំអាង ទៅលើភស្តុតាងដែលទទួលបានតាមរយៈការធ្វើទារុណកម្ម*



PRE-TRIAL CHAMBER CHAMBRE PRELIMINAIRE
E.C.C.C * C.E.T.C

ត្រូវបានផ្តល់ជូនទៅក្រមនៃសាលាក្តីអន្តរជាតិដទៃទៀតដែរ[២៨] (គឺសិទ្ធិដកចេញភស្តុតាងដែលបានស្នើឡើង) កាលណាភស្តុតាងនោះ "មិនត្រូវបានច្បាប់អនុញ្ញាត"[២៩]។ "ច្បាប់ជាធរមាន" នៅក្នុងប្រទេសកម្ពុជា រាប់បញ្ចូលទាំងលិខិតុបករណ៍អន្តរជាតិទាំងឡាយ ដូចជាអនុសញ្ញាប្រឆាំងអំពើទារុណកម្ម[៣០] ផងដែរ។

៣៦. មាត្រា ១៥ នៃអនុសញ្ញាប្រឆាំងអំពើទារុណកម្មចែងថា៖

"រដ្ឋភាគី ត្រូវធានាថា ឯកសាររាយការណ៍ទាំងឡាយ ដែលត្រូវបានកំណត់ថាបានបង្កើតឡើង/ បានមកពីអំពើទារុណកម្ម មិនអាចយកមកសំអាងជាភស្តុតាងក្នុងដំណើរការនីតិវិធីណាមួយឡើយ លើកលែងតែការប្រើប្រាស់ឯកសាររាយការណ៍នេះដើម្បីបញ្ជាក់ថា ការរាយការណ៍នេះត្រូវបានធ្វើ ឡើយដោយការប្រើទារុណកម្មដោយជនដែលត្រូវចោទថាបានប្រើទារុណកម្ម"។

៣៧. នៅថ្ងៃទី២៨ ខែតុលា ឆ្នាំ២០០៩ អង្គជំនុំជម្រះសាលាដំបូង បានកត់សំគាល់ក្នុងសេចក្តីសម្រេចមួយក្នុងរឿងក្តី កាំង ហ្គេចអ៊ាវ ហៅឌុច ចំពោះឯកសារដែលបានមកពីអំពើទារុណកម្មថា៖

"ឯកសារពាក់ព័ន្ធទាំងអស់នេះ មានកំណត់ត្រឹមតែអង្គហេតុដែលថាឯកសារទាំងនោះត្រូវបានបង្កើតឡើង និងក្នុងករណីដែលសមស្រប ធ្វើជាភស្តុតាងបង្ហាញថាឯកសារទាំងនោះត្រូវបានធ្វើឡើងដោយសារការធ្វើទារុណកម្ម។ ឯកសារទាំងនោះ គឺមិនអនុញ្ញាតអោយយកមកប្រើដើម្បីបញ្ជាក់ការពិតនោះទេ"[៣១]។

---

[២៨] វិធាន ៩៥ នៃវិធាននីតិវិធីនិងភស្តុតាងនៃសាលាក្តីព្រហ្មទណ្ឌអន្តរជាតិសំរាប់អតីតប្រទេសយូហ្គោស្លាវី និង សាលាក្តីព្រហ្មទណ្ឌអន្តរជាតិសំរាប់ប្រទេសរ៉្វាន់ដា។

[២៩] វិធាន ៨៧(៣)(ឃ) នៃវិធានផ្ទៃក្នុង។

[៣០] ប្រទេសកម្ពុជាបានធ្វើសច្ចាប័នអនុសញ្ញាប្រឆាំងអំពើទារុណកម្ម នៅថ្ងៃទី១៥ ខែតុលា ឆ្នាំ១៩៩២។

[៣១] ចូរអានសេចក្តីសម្រេចអង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០០៩ ឯកសារ E176 កថាខណ្ឌ ៨។



PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C C.E.T.C

៣៨. ទោះបីជាសហចៅក្រមស៊ើបអង្កេតមានសេចក្តីសង្កេតផ្ទុយពីនេះក្នុងដីកាសម្រេច[៣២]របស់ខ្លួនក្តី ក៏មាត្រា១៥ នៃអនុសញ្ញាប្រឆាំងនឹងអំពើទារុណកម្ម នឹងត្រូវយកមកអនុវត្តយ៉ាងហ្មឹងម៉ាត់។ គ្មានចន្លោះណាមួយដែលបើកលទ្ធភាពឲ្យមានការកំណត់ការពិត ឬឲ្យប្រើសេចក្តីថ្លែងការណ៍ដែលបានមកពីអំពើទារុណកម្មក្នុងវិធីផ្សេងពីនេះឡើយ[33]។ នៅពេលដែលខ្លួនបានទទួលបណ្តឹងឧទ្ធរណ៍ អង្គបុរេជំនុំជម្រះសង្កេតឃើញថា ដីកាសម្រេចច្បាប់ដើម និងអត្ថបទបកប្រែជាពីរភាសាទៀត មានអត្ថន័យមិនស្របគ្នាទេ ជាពិសេសកថាខណ្ឌខណ្ឌ២៨[34]ដែលមានសេចក្តីអធិប្បាយជាក់លាក់ក្នុងបណ្តឹងឧទ្ធរណ៍នេះ។ អង្គបុរេជំនុំជម្រះក៏សង្កេតឃើញផងដែរថា ដោយសារអត្ថន័យផ្ទុយគ្នានេះ ទើបនាំឲ្យមានភាពមិនច្បាស់លាស់ក្នុងការអនុវត្តមាត្រា១៥ នៃអនុសញ្ញាប្រឆាំងនឹងអំពើទារុណកម្ម ដែលពាក់ព័ន្ធនឹងភស្តុតាងដែលចោទជាបញ្ហាក្នុងដីកាសម្រេច។

---

[៣២] ដីកាសម្រេច កថាខណ្ឌ ២៨។

[៣៣] ប្រវត្តិនៃការរៀបចំសេចក្តីព្រាងមាត្រា ១៥ នៃអនុសញ្ញាប្រឆាំងនឹងអំពើទារុណកម្ម បញ្ជាក់ច្បាស់ពីបញ្ហានេះ។ ចូរអានឯកសារ អ.ស.ប UN Doc E/CN.4/1285, ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ១៩៧៨, សេចក្តីសង្ខេបរៀបចំដោយអគ្គលេខាធិការ អ.ស.ប អនុលោមតាមសេចក្តីសម្រេចរបស់គណកម្មាធិការ លេខ 18 (XXXIV), ឯកសារ អ.ស.ប UN Doc E/CN.4/1314, ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ១៩៧៨, ២២, ឯកសារ អ.ស.ប UN Doc E/CN.4/WG/1/WP.1, ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ១៩៧៩, ឯកសារ អ.ស.ប UN Doc E/CN.4/NGO/213, ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ១៩៧៨, គណកម្មាធិការសិទ្ធិមនុស្ស សេចក្តីសម្រេចលេខ 1 (XXXIV) ក្នុងកិច្ចប្រជុំលើកទី ១៥២៦ នៅថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ១៩៨០, គណកម្មាធិការសិទ្ធិមនុស្ស របាយការណ៍នៃក្រុមការងារស្តីពីការរៀបចំសេចក្តីព្រាងអនុសញ្ញាប្រឆាំងអំពើទារុណកម្ម និងការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មផ្សេងទៀតដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប លេខ E/CN.4/1367 ចុះថ្ងៃទី៥ ខែមីនា ឆ្នាំ១៩៨០, កថាខណ្ឌ ៨២។ ការបោះពុម្ពផ្សាយឡើងវិញរបស់គណកម្មាធិការសិទ្ធិមនុស្ស របាយការណ៍ស្តីពីកិច្ចប្រជុំលើកទី៣៦ ពីថ្ងៃទី៤ ខែកុម្ភៈ រហូតដល់ថ្ងៃទី១៤ ខែមីនា ឆ្នាំ១៩៨០ ឯកសារ អ.ស.ប UN Doc E/1980/13, E/CN.4/1408 កថាខណ្ឌ ២០៥ ទំព័រ ៥២-៧៣ កថាខណ្ឌ ៨៣។

[៣៤] អង្គបុរេជំនុំជម្រះកត់សំគាល់ឃើញថា បញ្ហានេះត្រូវបានកែតម្រូវក្នុង Zylab ចាប់តាំងពីមានសេចក្តីបង្គាប់ ប៉ុន្តែអត្ថបទក្នុងគេហទំព័រ អ.វ.ត.ក មិនទាន់បានកែតម្រូវនៅឡើយទេ។



E.C.C.C * C.E.T.C
PRE-TRIAL CHAMBER CHAMBRE PRELIMINAIRE

៣៩. អង្គបុរេជំនុំជម្រះយល់ឃើញថា សិទ្ធិរបស់ជនត្រូវចោទដែលមានចែងក្នុងវិធាន ២១ នៃវិធានផ្ទៃក្នុង ត្រូវបានការពារយ៉ាងគ្រប់គ្រាន់ដោយក្របខណ្ឌច្បាប់ជាធរមាន ដូចបានបញ្ជាក់ក្នុងសំអាងហេតុខាងលើ។ ហេតុដូច្នេះ អង្គបុរេជំនុំជម្រះយល់ឃើញថា វិធាន ២១ នៃវិធានផ្ទៃក្នុងមិនបានតម្រូវឲ្យខ្លួនបកស្រាយវិធានផ្ទៃក្នុង តាមវិធីដែលមានន័យថា ខ្លួនគប្បីប្រកាសថាបណ្ដឹងឧទ្ធរណ៍នេះអាចទទួលយកបានឡើយ។

**ហេតុដូច្នេះ អង្គបុរេជំនុំជម្រះសម្រេចជាឯកច្ឆ័ន្ទ៖**

មិនទទួលយកបណ្ដឹងឧទ្ធរណ៍នេះ។

ដោយអនុលោមតាមវិធាន ៧៧(១៣) នៃវិធានផ្ទៃក្នុង សាលដីកានេះបិទផ្លូវតវ៉ា។

**ភ្នំពេញ ថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ២០១០**

**អង្គបុរេជំនុំជម្រះ** **ប្រធាន**

PRE-TRIAL CHAMBER CHAMBRE PRELIMINAIRE E.C.C.C. C.E.T.C.

**Rowan DOWNING** **ន័យ ថុល** **Katinka LAHUIS** **ហួត វុទ្ធី** **ប្រាក់ គឹមសាន**